# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: មេធាវីការពារក្តី អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 31-Jan-2012, 10:16
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# សំណើរបស់អៀង សារី ស្នើសុំការបញ្ជាក់ពីការមិនអាចទាញសេចក្តីសន្និដ្ឋានដោយអវិជ្ជមានពីការនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទ នៅពេលជនជាប់ចោទប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតប

---

**ដាក់ដោយ ៖**

**មេធាវីការពារក្តី ៖**

អាង ឧត្តម

Michael G. KARNAVAS

**ចៅក្រមអង្គជំនុំជម្រះសាលាដំបូង ៖**

ចៅក្រម **និល ណុន**

ចៅក្រម **យ៉ូរ ឧត្តរា**

ចៅក្រម **យ៉ា សុខន**

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបម្រុង **ធូ មណី**

Original EN: 00769403-00769410

ចៅក្រមបម្រុង Claudia FENZ

**សហព្រះរាជអាជ្ញា÷**

ជា លាង

Andrew CAYLEY

**មេធាវីការពារក្ដីទាំងអស់**

**ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**

លោក អៀង សារី តាមរយៈសហមេធាវីការពារក្តីរបស់លោក "មេធាវីការពារក្តី" ចាប់ពីពេលនេះសូម ស្នើសុំការបញ្ជាក់ពីអង្គជំនុំជម្រះសាលាដំបូងថា គេអាច ហើយនឹងធ្វើការទាញសេចក្តីសន្និដ្ឋានដោយអវិជ្ជមានពីជនជាប់ចោទដែលប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតបដែរឬទេ។ ការស្នើសុំការបញ្ជាក់នេះត្រូវបានធ្វើឡើងជាចាំបាច់ ដោយផ្អែកលើ **ក.** មតិយោបល់នានាដែលធ្វើឡើងដោយលោក Tarik Abdulhak ជំនួយការអន្តរជាតិជាន់ខ្ពស់នៃការិយាល័យសហព្រះរាជអាជ្ញា ក្នុងអំឡុងពេលសវនាការ នៅថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១២ ដែល លោកបានស្នើថា គេអាចទាញសេចក្តីសន្និដ្ឋានដោយអវិជ្ជមានពីជនជាប់ចោទ ដែលមិនព្រមផ្តល់សក្ខីកម្ម[១] និង **ខ.** ការស្នើរបស់ចៅក្រម Lavergne ជាច្រើនដងដល់លោក ខៀវ សំផន ឲ្យធ្វើការ "បញ្ជាក់", "ផ្តល់យោបល់" ឬ"ឆ្លើយតប"ទៅនឹងសំណួរ និងឯកសារនានាដែលបានដាក់ចំពោះមុខគាត់ បន្ទាប់ពីគាត់បានប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់គាត់[២]។ ការបញ្ជាក់នេះកាន់តែជាការចាំបាច់ថែមទៀត ពីព្រោះថា លោក អៀង សារី បានបញ្ជាក់យ៉ាងច្បាស់ទៅអង្គជំនុំជម្រះសាលាដំបូងថា គាត់ប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតប[៣]។ មេធាវីការពារក្តីសូមលើកឡើងដោយក្តីគោរពថា ផ្អែកលើយុត្តិសាស្ត្រជាធរមានរបស់ អ.វ.ត.ក ជនជាប់ចោទមានសិទ្ធិនៅស្ងៀមមិនឆ្លើយតបដែលជាសិទ្ធិទទួលបានការការពារពីរដ្ឋធម្មនុញ្ញ និង សិទ្ធិមិនដាក់ពិរុទ្ធភាពមកលើខ្លួនឯង និងថា គេមិនអាចទាញការសន្និដ្ឋានដោយអវិជ្ជមានឡើយ ប្រសិនបើជនជាប់ចោទប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតបនោះ។

## I. សាវតារ

១. នៅថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១១, លោក អៀង សារី បានផ្តល់ការជូនដំណឹងថា លោកបានទទួលព័ត៌មានអំពីសិទ្ធិរបស់ខ្លួន និងថា "ខ្ញុំជូនដំណឹងដោយស្ម័គ្រចិត្ត ដោយចេតនា និងយ៉ាងច្បាស់

---

[១] "[លោក ABDULHAK ៖] តើ [លោក ខៀវ សំផន] បដិសេធមិនផ្តល់សក្ខីកម្ម និងប្រកាន់យកគោលជំហរថា លោកនឹងចេញសេចក្តីថ្លែងការណ៍ នៅពេលអង្គជំនុំជម្រះសាលាដំបូងបន្តអនុវត្តនីតិវិធីឬទេ? បើដូចនេះមែន ការិយាល័យសហព្រះរាជអាជ្ញានឹងធ្វើសេចក្តីសន្និដ្ឋានទាក់ទងនឹងការទាញយកសេចក្តីសន្និដ្ឋានដោយអវិជ្ជមានពីគោលជំហរដូចនេះ" ប្រតិចារឹក ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១២ លេខឯកសារ E1/26.1 ទំព័រ ៦១ បន្ទាត់ ៣ ដល់ ៦។

[២] ការឆ្លងឆ្លើយពាក្យសំដីទៅមករវាងអង្គជំនុំជម្រះសាលាដំបូង និងលោក ខៀវ សំផន នៅតែបន្តប្រហែលមួយម៉ោងទៀត។ *សូមមើល* ប្រតិចារឹក ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១២ ឯកសារ E1/26.1, ទំព័រ ៥៤ ដល់ ៧៥។

[៣] ការជូនដំណឹងរបស់លោក អៀង សារី ទៅអង្គជំនុំជម្រះសាលាដំបូងថា គាត់នឹងមិនផ្តល់សក្ខីកម្មទេ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២១០១១ លេខឯកសារលេខ E101/4.1។

លាស់ដល់អង្គជំនុំជម្រះសាលាដំបូងថា ខ្ញុំនឹងមិនផ្តល់សក្ខីកម្មទេ រួមទាំងការឆ្លើយទៅនឹងសំណួរណាមួយ ... ក្នុងពេលជំនុំជម្រះ ឬសវនាការជាដំណាក់កាលៗ នៅក្នុងសំណុំរឿង ០០២"[៤]។

២. នៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់នៅក្នុងអនុស្សរណៈមួយថា "នៅពេលនេះ សំណុំរឿង ០០២ ត្រូវបានបំបែកជាផ្នែកៗ ហើយការសួរដេញដោលនៅក្នុងសវនាការត្រូវអនុវត្តតាមចំណុចអង្គហេតុ ដែលបានបង្ហាញជូនភាគីទាំងអស់តាមរយៈឧបសម្ព័ន្ធ ឯកសារ E124/7 ដើម្បីធានាឲ្យមានលំដាប់លំដោយត្រឹមត្រូវក្នុងការសួរដេញដោលជនជាប់ចោទ សាក្សី អ្នកជំនាញ និងភាគីដើមបណ្តឹងរដ្ឋប្បវេណី។ ការសួរចម្លើយជនជាប់ចោទនឹងចាប់ផ្តើមនៅក្នុងសវនាការផ្នែកដំបូងនៅក្នុងសំណុំរឿង ០០២/០១ ស្តីពីប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា"[៥]។ មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា បន្ទាប់ពីបញ្ចប់ការសួរសំណួរលើជនជាប់ចោទអំពីប្រវត្តិបក្សកុម្មុយនីស្តកម្ពុជារួចហើយ អង្គជំនុំជម្រះនឹងបន្តសវនាការដំណាក់កាលបន្ទាប់ទៀត ដែលមានជាអាទិ៍ រចនាសម្ព័ន្ធរដ្ឋបាល និងរចនាសម្ព័ន្ធនៃការប្រាស្រ័យទាក់ទងការងារ[៦]។

៣. នៅរសៀលថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១២ បន្ទាប់ពីបង្គាប់ឲ្យនាំលោកខៀវ សំផន ទៅកាន់ឈើរាំងរង់ក្រចកសេះរួច លោកប្រធានអង្គជំនុំជម្រះ និល ណុន បានបញ្ជាក់ថា "ដោយឡែក លោក ខៀវ

---

[៤] *ដូចខាងលើ*។

[៥] អនុស្សរណៈរបស់មន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់នៃអង្គជំនុំជម្រះសាលាដំបូង ជូនចំពោះភាគីទាំងអស់នៅក្នុងសំណុំរឿង ០០២ ក្រោមកម្មវត្ថុ ៖ ការឆ្លើយតបទៅលើបញ្ហាដែលបានលើកឡើងដោយភាគីផ្សេងៗ មុនពេលសវនាការ និងការកំណត់ពេលវេលានៃកិច្ចប្រជុំមិនផ្លូវការជាមួយនឹងមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ លេខឯកសារ E141។

[៦] "នៅពេលសវនាការដំណាក់កាលដំបូងត្រូវបានបញ្ចប់ អង្គជំនុំជម្រះនឹងបន្តធ្វើសវនាការដំណាក់កាលបន្ទាប់ទៀតលើចំណុចអង្គហេតុដូចមានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ E124/7.2 (បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១) ដែលមានជាអាទិ៍ រចនាសម្ព័ន្ធរដ្ឋបាល និងរចនាសម្ព័ន្ធនៃការប្រាស្រ័យទាក់ទងការងារ (ដីកាដំណោះស្រាយកថាខណ្ឌ ៣៣-១១២)។ អង្គជំនុំជម្រះនឹងសួរសំណួរទៅជនជាប់ចោទលើចំណុចអង្គហេតុទាំងនេះ មុនពេលបន្តសំណួរទៅសាក្សីដែលមានរាយនាមខាងក្រោម"។ អនុស្សរណៈពីមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ជូនចំពោះភាគីទាំងអស់ក្នុងសំណុំរឿង ០០២ ក្រោមកម្មវត្ថុ ៖ ក្រុមសាក្សី និងអ្នកជំនាញ បន្ទាប់ដែលអង្គជំនុំជម្រះត្រូវស្តាប់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ ឯកសារ E155។

សំផន យើងបានប្រាប់លោករួចហើយអំពីសិទ្ធិរបស់លោក ហើយលោកមិនបានបង្ហាញបញ្ហានេះជាក់ច្បាស់ទេថាតើលោកនឹងប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតបឬយ៉ាងណា បើទោះបីយើងបានទទួលព័ត៌មានថា លោកនឹងប្រើសិទ្ធិនេះនៅពេលណាមានការបង្ហាញភស្តុតាងដោយសហព្រះរាជអាជ្ញាចំពោះរូបលោក គឺថាបង្ហាញភស្តុតាងដាក់បន្ទុកចំពោះលោក ទើបលោកឆ្លើយតប"[៧]។ ជាការឆ្លើយតប លោក គង់ សំអុន សហមេធាវីការពាក្ដីជាតិរបស់ លោក ខៀវ សំផន បានបញ្ជាក់ថា "*សូមអរគុណលោកប្រធាន។ តាមរយៈខ្ញុំ លោក ខៀវ សំផន បន្តប្រកាន់ជំហរមិនឆ្លើយតបទៅនឹងសំណួរនេះដូចដែលគាត់បានប្រកាស កាលពីថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១*"[៨]។

៤. បន្ទាប់ពីមានការបញ្ជាក់ដូចនេះរួចហើយ លោកប្រធានចៅក្រម និល ណុន បានប្រគល់វេទិកាទៅលោកចៅក្រម Lavergne ដើម្បីសួរសំណួរទៅកាន់ជនជាប់ចោទ ខៀវ សំផន[៩]។ មុនពេលលោកចៅក្រម Lavergne សួរសំណួរ លោក ខៀវ សំផន បានបញ្ជាក់ពីជំហររបស់លោកជូនអង្គជំនុំជម្រះសាលាដំបូងថា "*ខ្ញុំបានបញ្ជាក់យ៉ាងច្បាស់រួចហើយថា ខ្ញុំនឹងមិនឆ្លើយតបទៅនឹងសំណួរណាមួយទេ*"[១០]។ លោកប្រធានចៅក្រម និល ណុន ក៏បានបញ្ជាក់បន្ថែមថា លោក ខៀវ សំផន បានបញ្ជាក់ច្បាស់ហើយពីជំហរទាក់ទងនឹងចំណុចនេះ[១១] ប៉ុន្តែបានអនុវត្តផ្ទុយពីការយល់ឃើញរបស់លោកចៅក្រមចំពោះលោក ខៀវ សំផន ដោយសួរទៅកាន់ចៅក្រម Lavergne ថាតើនៅតែមានបំណងចង់តាំងសំណួរបន្ថែមទៀតចំពោះលោកខៀវ សំផន នៅពេលនោះដែរឬទេ"[១២]។ បន្ទាប់ពីបាន

---

[៧] ប្រតិចារិក ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១២ ឯកសារ E1/26.1, ទំព័រ ៥៤ បន្ទាត់ ១៧ ដល់ ២៣។

[៨] *ដូចខាងលើ* ទំព័រ ៥៥ បន្ទាត់ ៦ ដល់ ១០។

[៩] "ខ្ញុំសូមប្រគល់វេទិកាទៅលោកចៅក្រម Lavergne ដើម្បីបន្ត -- ឬសួរសំណួរទៅកាន់ជនជាប់ចោទ ខៀវ សំផន" *ដូចខាងលើ* ទំព័រ ៥៥ បន្ទាត់ ២៣ ដល់ ២៤។

[១០] *ដូចខាងលើ* ទំព័រ ៥៦ បន្ទាត់ ៥ ដល់ ៦។

[១១] "អរគុណលោក ខៀវ សំផន ដែលបានបញ្ជាក់សាជាថ្មីឱ្យកាន់តែច្បាស់ថែមទៀត។ យើងបានកត់សម្គាល់ឃើញថា លោកបានបង្ហាញជំហរច្បាស់លាស់ហើយលើអង្គហេតុទាក់ទងនឹងការឆ្លើយទៅនឹងសំណួរនានាអំពីប្រវត្តិបក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យទ"។ *ដូចខាងលើ* ទំព័រ ៥៧ បន្ទាត់ ២ ដល់ ៦។

[១២] *ដូចខាងលើ* ទំព័រ ៥៧ បន្ទាត់ ៧ ដល់ ៨។

ទទួលស្គាល់ពីជំហាររបស់លោក ខៀវ សំផន[១៣] លោកចៅក្រម Lavergne ក៏បានស្នើឲ្យមាន "ការបញ្ជាក់មួយចំនួនទាក់ទងនឹងការអត្ថាធិប្បាយនានាដែលគាត់បានធ្វើ នៅខែ ធ្នូ។ បន្ទាប់មក ... យើងនឹងផ្តល់ឱកាសជូនលោកដើម្បីធ្វើអត្ថាធិប្បាយ[ចំពោះឯកសារទាំងនេះ]"[១៤]។ ជាថ្មីម្តងទៀត លោក គង់ សំអុន បានបញ្ជាក់សាជាថ្មីនូវជំហាររបស់ លោក ខៀវ សំផន ថា គាត់នឹងមិនឆ្លើយតបទៅនឹងសំណួរណាមួយឡើយ[១៥]។

៥. បន្ទាប់ពីការឆ្លើយឆ្លងពាក្យសំដីរវាងអង្គជំនុំជម្រះសាលាដំបូង, លោក ខៀវ សំផន និងលោក គង់ សំអុន ក.ស.ព តាមរយៈ លោក Abdulhak បានបញ្ជាក់ថា "តើ[លោក ខៀវ សំផន] នឹងបដិសេធមិនផ្តល់សក្ខីកម្ម ហើយបន្តប្រកាន់ជំហារថា លោកនឹងធ្វើការឆ្លើយតបនៅពេលសវនាការបន្តទៅមុខទៀត? ប្រសិនបើអញ្ចឹងមែននោះ ការិយាល័យសហព្រះរាជអាជ្ញាអាចនឹងទាញសេចក្តីសន្និដ្ឋានដោយអវិជ្ជមានពីការប្រកាន់ជំហារដូចនេះ"[១៦]។

៦. ក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីចំនួនមួយម៉ោងក្រោយមក ការផ្លាស់ប្តូរពាក្យសំដីទៅវិញទៅមក រវាងចៅក្រម Lavergne លោក ខៀវ សំផន និងលោក គង់ សំអុន នៅតែបន្ត។ ចៅក្រម Lavergne បានស្នើឲ្យលោក ខៀវ សំផន ធ្វើការ "បញ្ជាក់", "ផ្តល់យោបល់" ឬ "ឆ្លើយតប" ទៅនឹងសំណួរ និងឯកសារផ្សេងៗ មិនតិចជាង ៨ ដងទេ ដែលមានជាអាទិ៍ ៖

---

[១៣] "លោក ខៀវ សំផន, ខ្ញុំជឿថា យើងទាំងអស់គ្នាដឹងហើយអំពីជំហាររបស់លោក"។ *ដូចខាងលើ* ទំព័រ ៥៨ បន្ទាត់ ១១ ដល់ ១២។

[១៤] *ដូចខាងលើ* ទំព័រ ៥៨ បន្ទាត់ ២៣ ដល់ ២៥; *ដូចខាងលើ* ទំព័រ ៥៩ បន្ទាត់ ៥ ដល់ ៦។

[១៥] "សូមអរគុណលោកប្រធាន។ ក្រោយពីបានស្តាប់យោបល់របស់លោកចៅក្រម Lavergne, ខ្ញុំបាទមានពីរចំណុចដែលត្រូវលើកក្នុងសំណើរបស់ខ្ញុំ។ ទីមួយ សូមបញ្ជាក់ថា លោកខៀវ សំផន បានបោះបង់សិទ្ធិមិនឆ្លើយតបទៅនឹងសំណួរទាំងឡាយ ដែលនឹងលើកឡើង ទាក់ទងនឹងប្រវត្តិសាវតារនេះរួចហើយ។ ហើយលោកចៅក្រមក៏បានបញ្ជាក់ថា លោកបានយល់ដឹងនូវចំណុចទាំងនេះដែរ។ ដូច្នេះ ខ្ញុំសូមសំណូមពរថាមិនគួរមានសំណួរអ្វីនឹងត្រូវលើកដាក់តាំងទៅនឹងលោក ខៀវ សំផន ទាក់ទងនឹងសាវតារនេះទេ"។ *ដូចខាងលើ* ទំព័រ ៥៩ បន្ទាត់ ១៧ ដល់ ២៤។

[១៦] *ដូចខាងលើ* ទំព័រ ៦១ បន្ទាត់ ៣ ដល់ ៦។

- "ជាបឋម បន្ទាប់ពីស្តាប់ឮយោបល់របស់លោក យើងចង់បានសេចក្តីបំភ្លឺមួយចំនួនពាក់ព័ន្ធទៅនឹងការអត្ថាធិប្បាយរបស់លោក ដែលបានធ្វើឡើងនៅខែ ធ្នូ"[១៧]

- "នេះគឺជាមូលហេតុ ដែលឯកសារទាំងនេះត្រូវដាក់ជូនលោក ហើយអាចថា សម្រង់អត្ថបទនឹងត្រូវបានអានជូនលោក និងផ្តល់ឱកាសឲ្យលោកក្នុងការផ្តល់អត្ថាធិប្បាយទៅលើឯកសារទាំងអស់នេះ"[១៨]

- "ដូចនេះ នៅពេលនេះ យើងគ្រាន់តែនិយាយអំពីការពន្យល់បំភ្លឺ។ ខ្ញុំមិនសួរសំណួរភ្លាមៗទេ។ អ្វីៗដែលខ្ញុំចង់ពន្យល់បង្ហាញនោះគឺថា អង្គជំនុំជម្រះនឹងពិចារណាទៅលើឯកសារមួយចំនួនដែលបានដាក់បញ្ចូលទៅក្នុងសំណុំរឿងរួចហើយ។ អង្គជំនុំជម្រះយល់ឃើញថា ឯកសារទាំងអស់នេះអាចមានការជាប់ពាក់ព័ន្ធ។ ឯកសារទាំងនេះនឹងត្រូវយកមកបង្ហាញនៅក្នុងអង្គសវនាការ និងត្រូវយកមកបង្ហាញជូនលោកខៀវ សំផន។ [១៤.0២.៥៥]។ លោក ខៀវ សំផន មានឱកាសផ្តល់យោបល់ដល់ឯកសារទាំងនេះ ហើយប្រសិនបើគាត់ចង់ គាត់អាចផ្តល់យោបល់លើឯកសារទាំងនេះ"[១៩],

- "អរគុណលោកប្រធាន។ ដូច្នេះ ឯកសារដែលនឹងអាននេះ គឺនឹងអាចអនុញ្ញាតឲ្យលោក ខៀវ សំផន ផ្លាស់ប្តូរយោបល់ និងយល់អំពីកម្មវត្ថុនៃគោលបំណងនៃសវនាការនេះ"[២០],

- "ខ្ញុំគិតថា អ្វីដែលអាចជួយយើងបាននោះ គឺសូមលោកឆ្លើយទៅនឹងអ្វីដែលខ្ញុំចង់ចោទសួរ"[២១],

---

[១៧] *ដូចខាងលើ* ទំព័រ ៥៨ បន្ទាត់ ២៣ ដល់ ២៥។

[១៨] *ដូចខាងលើ* ទំព័រ ៥៩ បន្ទាត់ ៤ ដល់ ៦។

[១៩] *ដូចខាងលើ* ទំព័រ ៦៤ បន្ទាត់ ១៤ ដល់ ២៣។

[២០] *ដូចខាងលើ* ទំព័រ ៦៥ បន្ទាត់ ១៩ ដល់ ២១។

[២១] *ដូចខាងលើ* ទំព័រ ៦៨ បន្ទាត់ ៧ ដល់ ៨។

- "លោកប្រធាន ខ្ញុំមិនដឹងថាតើខ្ញុំអាចសួរសំណួរដល់លោក ខៀវ សំផន ថាតើគាត់តាមពិតជាអ្នកនិពន្ធនៃអត្ថបទសម្រាំងនេះឬយ៉ាងណា, ថាតើគាត់មានអត្ថាធិប្បាយលើអត្ថបទសម្រាំងនេះ ឬក៏ខ្ញុំមិនត្រូវសួរសំណួរអ្វីទាំងអស់នោះ"[២២],

- "ដូច្នេះ ខ្ញុំមិនសួរសំណួរលោកទេ។ ខ្ញុំគ្រាន់តែចង់សួរថា តើលោកមានអ្វីដែលត្រូវផ្តល់ការអត្ថាធិប្បាយទៅលើឃ្លាដែលលោកបានសរសេរដោយផ្ទាល់ដែរឬទេ"[២៣],

- "ដូច្នេះ នេះជាសំណួរដដែលទេ។ តើលោកមានយោបល់លើឃ្លាទាំងនេះទេ?"[២៤]

៧. ជាការឆ្លើយតបទៅនឹងការចោទសួរម្តងៗ លោកខៀវ សំផន និងលោក គង់ សំអុន បានបញ្ជាក់ពីជំហរដដែលៗថា លោក ខៀវ សំផននឹងមិននិយាយឡើយ។

- "[លោក គង់ សំអុន ៖] សូមអរគុណលោកប្រធាន។ ក្រោយពីបានស្តាប់យោបល់របស់លោកចៅក្រម Lavergne, ខ្ញុំបាទមានពីរចំណុចដែលត្រូវលើកក្នុងសំណើរបស់ខ្ញុំ។ ទីមួយ សូមបញ្ជាក់ថា លោកខៀវ សំផន បានបោះបង់សិទ្ធិមិនឆ្លើយតបទៅនឹងសំណួរទាំងឡាយ ដែលនឹងលើកឡើង ទាក់ទងនឹងប្រវត្តិសាវតារនេះរួចហើយ។ ហើយលោកចៅក្រមក៏បានបញ្ជាក់ថា លោកបានយល់ដឹងនូវចំណុចនេះដែរ។ ដូច្នេះ ខ្ញុំសូមសំណូមពរថាមិនគួរមានសំណួរអ្វីនឹងត្រូវលើកដាក់តាំងទៅនឹងលោក ខៀវ សំផន ទាក់ទងនឹងសាវតារនេះទេ"[២៥],

- "លោក ខៀវ សំផន ៖ សូមគោរពលោកប្រធាន! ខ្ញុំបាទបានជម្រាបតាំងពីថ្ងៃទី ១៣ ខែ ធ្នូ ម្តេះថា ខ្ញុំសូមមិនទាន់ឆ្លើយនឹងសំណួរអ្វីទាំងអស់ ហើយខ្ញុំពុំមានអ្វីថែមថយលើសេចក្តីថ្លែងការណ៍របស់ខ្ញុំថ្ងៃទី ១៣ ខែ ធ្នូ នោះទេ។ អាហ្នឹងខ្ញុំសូមជម្រាមបញ្ជាក់បន្ថែមប៉ុណ្ណឹង។ ដូចនេះ សូម

---

[២២] *ដូចខាងលើ* ទំព័រ ៧១ បន្ទាត់ ១៣ ដល់ ១៦។

[២៣] *ដូចខាងលើ* ទំព័រ ៧៣ បន្ទាត់ ១៨ ដល់ ១៩។

[២៤] *ដូចខាងលើ* ទំព័រ ៧៤ បន្ទាត់ ២៣។

[២៥] *ដូចខាងលើ* ទំព័រ ៥៩ បន្ទាត់ ១៧ ដល់ ២៤។

ទោសលោកចៅក្រម Lavergne កុំឲ្យខាតពេលលើសំណួរអីវែងឆ្ងាយ ខ្ញុំសូមជម្រាបថា ខ្ញុំនឹងមិនមានអីថែមថយទៀតទេ ក្រៅពីសេចក្ដីថ្លែងការណ៍ដែលខ្ញុំបានធ្វើរួចហើយនោះ"[២៦],

- "លោក គង់ សំអុន ៖ សូមអរគុណលោកប្រធាន (ផ្អាកមួយភ្លែត) (១៤:0៧:២១) សូមអរគុណលោកប្រធាន។ ក្រោយពីការពិភាក្សាជាមួយលោក ខៀវ សំផន គាត់បានបញ្ជាក់ប្រាប់ខ្ញុំថា គាត់នឹងមិនឆ្លើយសំណួរទាំងអស់ ដែលនឹងដាក់មក ទាក់ទងនឹងប្រវត្តិសាវតារនេះ។ អរគុណលោកប្រធាន"[២៧],

- "លោក គង់ សំអុន ៖ សូមអរគុណលោកប្រធាន។ ខ្ញុំបាទសូមបញ្ជាក់សាឡើងវិញពីជំហររបស់លោក ខៀវ សំផន។ លោកបានបញ្ជាក់ថា លោកនឹងមិនឆ្លើយអ្វីបន្ថែមទៀតទេ អម្បាញ់មិញនេះក៏លោកបានបញ្ជាក់ដែរ"[២៨],

- "លោក គង់ សំអុន ៖ ខ្ញុំសូមបញ្ជាក់ថា មូលហេតុនៃការស្នើសុំសំណួរនេះគឺដោយសារលោក ខៀវ សំផន បានបដិសេធមិនព្រមឆ្លើយ ហើយបើគាត់មិនឆ្លើយហើយ ហើយលោកសួរដដែល ៗថែមទៀតនោះ អាហ្នឹងទៅជា ... ដូចជាអាចថាជាការរំខានមិនគោរពសិទ្ធិនៃការមិនឆ្លើយតបរបស់លោក ខៀវ សំផន"[២៩],

- "លោក គង់ សំអុន ៖ សូមអរគុណលោកប្រធាន។ ខ្ញុំបាទសូមអនុញ្ញាតលោកប្រធានមេត្តាកុំឲ្យលោកចៅក្រម Lavergne លើកតាំងជាសំណួរចំពោះលោក ខៀវ សំផន តទៅទៀត ហើយដោយលោកបានបញ្ជាក់ជាច្រើនដងហើយថា លោកសុំមិនឆ្លើយតបទៅនឹងសំណួរទាំងអស់នោះទេ។ ដូចនេះ ការព្យាយាមតាំងសំណួរដដែលនេះអាចធ្វើឲ្យគាត់ភ័ន្តច្រឡំ ហើយឆ្លើយនូវចំណុច

---

[២៦] *ដូចខាងលើ* ទំព័រ ៦១ បន្ទាត់ ២៥ ដល់ ទំព័រ ៦២ បន្ទាត់ ៤។

[២៧] *ដូចខាងលើ* ទំព័រ ៦៥ បន្ទាត់ ១១ ដល់ ១៧។

[២៨] *ដូចខាងលើ* ទំព័រ ៦៨ បន្ទាត់ ១៧ ដល់ ២១។

[២៩] *ដូចខាងលើ* ទំព័រ ៦៩ បន្ទាត់ ២២ ដល់ ទំព័រ ៧0 បន្ទាត់ ១។

ដែលធ្វើឲ្យប៉ះពាល់ដល់ទៅលើការប្រើសិទ្ធិដែលជាសិទ្ធិស្របច្បាប់របស់គាត់។ សូមអរគុណ”[៣០],

- “លោក ខៀវ សំផន ៖ សូមគោរពលោកប្រធាន។ ខ្ញុំបាទអត់មានអត្ថាធិប្បាយអីថែមទៀតលើអ្វីដែលខ្ញុំសរសេរនោះទេ”[៣១],

- “លោក គង់ សំអុន ៖ សូមអរគុណលោកប្រធាន។ ជាថ្មីម្តងទៀត ខ្ញុំសូមបញ្ជាក់ថា លោក ខៀវ សំផន កំពុងប្រើសិទ្ធិមិនឆ្លើយតប ហើយសិទ្ធិនេះត្រូវតែគោរព ពីព្រោះច្បាប់របស់យើងបានផ្តល់សិទ្ធិនេះឲ្យទៅគាត់”[៣២]

## II. ទឡ្ហីករណ៍ និងច្បាប់ជាធរមាន

### ក. ជនជាប់ចោទមានសិទ្ធិនៅស្ងៀមមិនឆ្លើយតប និងសិទ្ធិមិនដាក់ពិរុទ្ធភាពមកលើខ្លួនឯង

៨. យោងតាមមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា “ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ”[៣៣]។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (“ICCPR”) ផ្តល់ការធានាថា បុគ្គលម្នាក់ៗនឹង “មិនត្រូវបានបង្ខិតបង្ខំឲ្យឆ្លើយដាក់កំហុសលើខ្លួនឯង ឬសារភាពថាមានពិរុទ្ធឡើយ”[៣៤]។ យោងតាមកិច្ចព្រមព្រៀង អ.វ.ត.ក ត្រូវអនុវត្តយុត្តាធិការរបស់ខ្លួន ដូចមានចែងនៅក្នុងមាត្រា ១៤

---

[៣០] *ដូចខាងលើ* ទំព័រ ៧២ បន្ទាត់ ២ ដល់ ៧។

[៣១] *ដូចខាងលើ* ទំព័រ ៧៣ បន្ទាត់ ២១ ដល់ ២៣។

[៣២] *ដូចខាងលើ* ទំព័រ ៧៥ បន្ទាត់ ១ ដល់ ៥។

[៣៣] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើវិសោធនកម្ម ចុះថ្ងៃទី ៤ ខែមីនា ឆ្នាំ ១៩៩៩ (“រដ្ឋធម្មនុញ្ញកម្ពុជា”)។

[៣៤] កតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៤(៣)(ផ)។

និងមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[៣៥]។ ជំហរនេះត្រូវបាន បញ្ជាក់ម្តងទៀតនៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[36]។ វិធាន ២១(១)(ឃ)នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ("វិធាន") ចែងថា នៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី ជនជាប់ចោទ មានសិទ្ធិនៅស្ងៀមមិនឆ្លើយតប[៣៧]។

៩. សិទ្ធិរបស់ជនជាប់ចោទក្នុងការនៅស្ងៀមមិនឆ្លើយតប និងសិទ្ធិមិនដាក់ពិរុទ្ធភាពមកលើខ្លួនឯងត្រូវ បានធានាយ៉ាងច្បាស់លាស់នៅ អ.វ.ត.ក តាមរយៈរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា កតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ កិច្ចព្រមព្រៀង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង។ សំណើឲ្យធ្វើការ "បញ្ជាក់" "ផ្តល់យោបល់" ឬ "ឆ្លើយតប" ទៅនឹង សំណួរ ឬឯកសារនានា គឺជាសំណើសុំឲ្យនិយាយ ពីព្រោះជនជាប់ចោទមិនអាច "បញ្ជាក់", "ផ្តល់ យោបល់", ឬ "ឆ្លើយតប" ដោយមិននិយាយបានឡើយ។ មេធាវីការពារក្តីយល់ឃើញថា នៅពេល ណាជនជាប់ចោទបានបញ្ជាក់យ៉ាងច្បាស់លាស់ក្នុងការប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតបនោះ សំណើ សុំធ្វើការ "បញ្ជាក់", "ផ្តល់យោបល់", ឬ "ឆ្លើយតប" ទៅនឹងសំណួរ ឬឯកសារ គឺជាការបំពាន ដល់សិទ្ធិជាសារវ័ន្តរបស់ជនជាប់ចោទ ដែលជាសិទ្ធិទទួលបានការការពារពីរដ្ឋធម្មនុញ្ញក្នុងការនៅ ស្ងៀមមិនឆ្លើយតប និងសិទ្ធិមិនដាក់ពិរុទ្ធភាពមកលើខ្លួនឯង។

---

[៣៥] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវ ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២00៣ ("កិច្ចព្រម ព្រៀង"), មាត្រា ១៣។

[៣៦] ច្បាប់ស្តីពីការបង្កើតឱមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុង រយៈពេលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២00៤ ("ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក") មាត្រា ៣៣(ថ្មី) មាត្រា ៣៥(ថ្មី)។

[៣៧] មាត្រា ២១(១)(ឃ) ចែងថា "ជនណាដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់ ត្រូវចាត់ទុកថាគ្មានទោស ដរាបណា ពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ ។ ជនទាំងនេះមានសិទ្ធិទទួលដំណឹងអំពីបទល្មើសដែលចោទប្រកាន់ចំពោះខ្លួន និង មានមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន ហើយនិងនៅក្នុងគ្រប់ដំណាក់កាល ទាំងអស់នៃកិច្ចដំណើរការនីតិវិធីត្រូវផ្តល់ ព័ត៌មានដល់គេ អំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប"។

## ខ. គេមិនអាចទាញសេចក្តីសន្និដ្ឋានដោយអវិជ្ជមានពីការនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទឡើយ

១០. មេធាវីការពារក្តីយល់ឃើញថា នៅពេលជនជាប់ចោទប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតបនោះ គេមិនអាចទាញសេចក្តីសន្និដ្ឋានដោយអវិជ្ជមានពីការនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទនោះទេ។ សិទ្ធិរបស់ជនជាប់ចោទក្នុងការនៅស្ងៀមមិនឆ្លើយតបមិនអាចមានន័យពេញលេញឡើយ នៅពេលការប្រើសិទ្ធិនេះ នាំឲ្យមានការស្តីបន្ទោសចំពោះការប្រើសិទ្ធិនេះ។ ការទាញសេចក្តីសន្និដ្ឋានដោយអវិជ្ជមាន នៅពេលជនជាប់ចោទបានប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតបនោះ គឺជាការបំពានដល់សច្ចធារណ៍នៃនិរទោស និងផ្ទេរបន្ទុកស្វែងរកភស្តុតាងពីការិយាល័យសហព្រះរាជអាជ្ញាទៅជាបន្ទុករបស់មេធាវីការពារក្តី[៣៨]។

១១. នៅ អ.វ.ត.ក ជនជាប់ចោទមានសិទ្ធិដែលទទួលបានការការពារពីរដ្ឋធម្មនុញ្ញ ក្នុងការឲ្យគេចាត់ទុកថាគ្មានទោស រហូតទាល់តែមានការបង្ហាញពីពិរុទ្ធភាព[៣៩]។ ការស្វែងរកភស្តុតាងគឺជាបន្ទុក

[៣៨] "ការអនុញ្ញាតឲ្យទាញការសន្និដ្ឋានដោយអវិជ្ជមានពីសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទហាក់ដូចជាការបង្ខំដែលមានអនុភាពកែប្រែបន្ទុករកភស្តុតាងពីរដ្ឋអាជ្ញាទៅជាបន្ទុករបស់ជនជាប់ចោទ ដូចនេះ មិនស្របគ្នានឹងសិទ្ធិនេះឡើយ" NIHAL JAYAWICKRAMA, THE JUDICIAL APPLICATION OF HUMAN RIGHTS LAW: NATIONAL, REGIONAL AND INTERNATIONAL JURISPRUDENCE 581 (CAMBRIDGE UNIVERSITY PRESS, 2002)។

[៣៩] រដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ៣៨ ចែងក្នុងផ្នែកពាក់ព័ន្ធថា "ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ", មាត្រា ១១(១)របស់សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR) ចែងថា "ជនដែលជាប់ចោទពីបទព្រហ្មទណ្ឌត្រូវចាត់ទុកថាជាជនគ្មានទោស រហូតដល់ពិរុទ្ធភាពត្រូវបានរកឃើញ នៅក្នុងសវនាការជាសាធារណៈ ដែលមានការធានាចាំបាច់ដើម្បីឲ្យជននោះការពារខ្លួន", មាត្រា ១៤(២)នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយចែងថា "ជនដែលជាប់ចោទពីបទព្រហ្មទណ្ឌត្រូវបានចាត់ទុកថាជាជនគ្មានទោស រហូតដល់ពិរុទ្ធភាពរបស់ខ្លួនត្រូវបានកំណត់ស្របតាមច្បាប់", មាត្រា ១៣(១)នៃកិច្ចព្រមព្រៀងចែងក្នុងផ្នែកពាក់ព័ន្ធថា "សិទ្ធិរបស់ជនជាប់ចោទដែលមានចែងនៅក្នុងមាត្រា ១៤ និងមាត្រា ១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវតែបានគោរពនៅគ្រប់ពេលក្នុងដំណើរការនៃការជំនុំជម្រះក្តី។ សិទ្ធិបែបនេះជាពិសេសសិទ្ធិ ... ត្រូវបានចាត់ទុកថាគ្មានទោសពែរហូតដល់ពេលរកឃើញថាមានជាប់ពិរុទ្ធ", មាត្រា ៣៥ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងត្រង់ផ្នែកពាក់ព័ន្ធថា "ជនជាប់ចោទណាក៏ដោយត្រូវចាត់ទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ"។ វិធាន ២១(ឃ)នៃវិធានផ្ទៃក្នុងចែងត្រង់ផ្នែកពាក់ព័ន្ធថា "ជនណាដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់ ត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ"។

របស់ការិយាល័យសហព្រះរាជអាជ្ញា ក្នុងការបង្ហាញពីពិរុទ្ធភាពរបស់ជនជាប់ចោទឲ្យលើសពីវិមតិសង្ស័យ[៤០]។ ប្រសិនបើធ្វើការទាញសេចក្ដីសន្និដ្ឋានដោយអវិជ្ជមានពីជនជាប់ចោទដែលនៅស្ងៀមមិនឆ្លើយតបនោះ, ជនជាប់ចោទអាចមានអារម្មណ៍ថា គាត់ត្រូវបានបង្ខំឲ្យនិយាយដើម្បីតែរក្សាសច្ចធារណ៍នៃនិរទោសណាមួយប៉ុណ្ណោះ។ គេអាចនិយាយម្យ៉ាងទៀតថា វាហាក់ដូចជាថា ក.ស.ព ស្នើថា ការនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទ ឬការបញ្ជាក់ម្ដងហើយម្ដងទៀតរបស់ជនជាប់ចោទក្នុងការប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតប អាចធ្វើឲ្យការស្វែងរកភស្តុតាងទៅជាបន្ទុករបស់ជនជាប់ចោទទៅវិញ។

១២. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា កិច្ចព្រមព្រៀង ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង មិនបានចែងពីការអាចទាញសេចក្ដីសន្និដ្ឋានដោយអវិជ្ជមានពីការនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទទេ។ យុត្តិសាស្ត្រស្ដីពីបញ្ហានេះពុំមាននៅក្នុងសំណុំរឿង 00១ ពីព្រោះ ឌុច មិនបានប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតបឡើយ។ ការណែនាំលើបញ្ហានេះអាចដកស្រង់ចេញពីលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC") និងយុត្តិសាស្ត្រពីតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ("ICTY")។ មាត្រា ៦៧(១)(ឆ)នៃលក្ខន្តិកៈ ICC ចែងថា ជនជាប់ចោទត្រូវមានសិទ្ធិ ៖ "មិនត្រូវបង្ខិតបង្ខំឲ្យផ្ដល់សក្ខីកម្ម ឬសារភាពពីពិរុទ្ធភាព និងត្រូវមានសិទ្ធិនៅស្ងៀមមិនឆ្លើយតប ដោយការនៅស្ងៀមមិនឆ្លើយតបដូចនេះមិនត្រូវប្រើជាកត្តាមួយក្នុងការកំណត់ពីពិរុទ្ធភាព ឬភាពគ្មានទោសឡើយ"។ នៅក្នុងរឿងក្ដី *Čelebići* អង្គជំនុំជម្រះតុលាការកំពូលរបស់ ICTY បានសម្រេចថា ៖

> ទាំងលក្ខន្តិកៈ ទាំងវិធានរបស់តុលាការនេះ មិនបានចែងឲ្យបានច្បាស់ពីការអាចទាញសេចក្ដីសន្និដ្ឋានពីការខកខានរបស់ជនជាប់ចោទក្នុងការផ្ដល់ភស្តុតាងនោះទេ។ ក្នុងពេលជាមួយគ្នានោះ ទាំងលក្ខន្តិកៈ ទាំងវិធានមិនបានចែងថា ការនៅស្ងៀមមិនឆ្លើយតបមិនគួរ "ចាត់ទុកជាកត្តាមួយក្នុងការកំណត់ពីពិរុទ្ធភាព ឬភាពគ្មានទោសឡើយ"។ ប្រសិនបើមានបំណងថាលទ្ធផលមិនល្អបែបនេះអាចនឹងមាន... នោះលក្ខន្តិកៈអាចមានការចែង និងការព្រមានច្បាស់លាស់

[៤០] វិធាន ៨៧(១) ចែងត្រង់ផ្នែកពាក់ព័ន្ធថា "សហព្រះរាជអាជ្ញាមានបន្ទុកបញ្ជាក់ពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ ដើម្បីផ្ដន្ទាទោសជនជាប់ចោទ អង្គជំនុំជម្រះសាលាដំបូងត្រូវមានជំនឿ ដោយគ្មានវិមតិសង្ស័យអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ"។

ដោយមានចែងពីការការពារសមស្រប។ ដូចនេះ ... លក្ខន្តិកៈ និងវិធាន មានចែងពីការហាមឃាត់ដាច់ខាតប្រឆាំងនឹងការចាត់ទុកការនៅស្ងៀមមិនឆ្លើយតប ជាកត្តាមួយក្នុងការកំណត់ពីពិរុទ្ធភាព ឬភាពគ្មានទោស...[៤១]។

១៣. នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ព័ត៌មានដល់ភាគីទាំងអស់ថា អង្គជំនុំជម្រះនឹងសួរជនជាប់ចោទលើចំណុចអង្គហេតុមួយម្តងៗ។ សក្ខីកម្មរបស់ជនជាប់ចោទត្រូវបានបំបែកជាចំណុចអង្គហេតុនានាទាក់ទងនឹងខ្លួនគាត់ផ្ទាល់។ ឧទាហរណ៍ ចំណុចអង្គហេតុដំបូងគឺ "ប្រវត្តិបក្សកុម្មុនីស្តកម្ពុជា"[៤២], ចំណុចអង្គហេតុទីពីរ គឺ "រចនាសម្ព័ន្ធរដ្ឋបាល និងរចនាសម្ព័ន្ធនៃការប្រាស្រ័យទាក់ទង"[៤៣]។ ជនជាប់ចោទអាចមានបំណងផ្តល់សក្ខីកម្មទៅលើចំណុចអង្គហេតុមួយ ប៉ុន្តែមិនផ្តល់សក្ខីកម្មលើចំណុចអង្គហេតុផ្សេងទៀតទេ។ ប្រសិនបើជនជាប់ចោទសម្រេចផ្តល់សក្ខីកម្មលើចំណុចអង្គហេតុមួយ ប៉ុន្តែមិនផ្តល់សក្ខីកម្មលើចំណុចអង្គហេតុផ្សេងទៀតនោះ មេធាវីការពារក្តីសន្និដ្ឋានថា គេមិនអាចទាញសេចក្តីសន្និដ្ឋានដោយអវិជ្ជមានពីចំណុចអង្គហេតុដែលជនជាប់ចោទនៅស្ងៀមមិនឆ្លើយតបឡើយ។

## III. សេចក្តីសន្និដ្ឋាន

---

[៤១] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Delalić និងមនុស្សផ្សេងទៀត.*, IT-96-21-A, សាលក្រម ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០១ កថាខណ្ឌ ៧៨៣។

[៤២] អនុស្សរណៈរបស់មន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់នៃអង្គជំនុំជម្រះសាលាដំបូង ជូនចំពោះភាគីទាំងអស់នៅក្នុងសំណុំរឿង ០០២ ក្រោមកម្មវត្ថុ ៖ ការឆ្លើយតបទៅលើបញ្ហាដែលបានលើកឡើងដោយភាគីផ្សេងៗ មុនពេលសវនាការ និងការកំណត់ពេលវេលានៃកិច្ចប្រជុំមិនផ្លូវការជាមួយនឹងមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ E141។

[៤៣] អនុស្សរណៈរបស់មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងជូនចំពោះភាគីទាំងអស់ក្នុងសំណុំរឿង ០០២ ក្រោមកម្មវត្ថុ ៖ ក្រុមសាក្សី និងអ្នកជំនាញបន្ទាប់ដែលអង្គជំនុំជម្រះត្រូវស្តាប់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ ឯកសារ E155។

១៤. ដោយសារជំហររបស់ ក.ស.ព ដូចដែល ក.ស.ព[៤៤] និងដើមបណ្តឹងរដ្ឋប្បវេណី[៤៥] បានលើកឡើងពីមុនមក គេអាចទាញសេចក្តីសន្និដ្ឋានដោយអវិជ្ជមានពីការប្រើប្រាស់សិទ្ធិមិនឆ្លើយតបនោះ វាជាការសំខាន់សម្រាប់មេធាវីការពារក្តីក្នុងការស្វែងរកការបញ្ជាក់ថាតើជនជាប់ចោទនៅ អ.វ.ត.ក មានសិទ្ធិនៅស្ងៀមមិនឆ្លើយតប និង មានសិទ្ធិមិនដាក់ពិរុទ្ធភាពលើខ្លួនឯង និងថាគេមិនអាចទាញសេចក្តីសន្និដ្ឋានដោយអវិជ្ជមានឡើយ នៅពេលជនជាប់ចោទប្រើសិទ្ធិទាំងនេះ។ មេធាវីការពារក្តីស្នើសុំការបញ្ជាក់ពីអង្គជំនុំជម្រះសាលាដំបូងថា តើជំហររបស់មេធាវីការពារក្តីដូចមានចែងនៅក្នុង

---

[៤៤] "[លោក ច័ន្ទ តារាស្មី ៖] នៅក្នុងបរិបទនៃការជំរុញឲ្យមានសវនាការឆាប់រហ័សប្រកបដោយយុត្តិធម៌ និងត្រឹមត្រូវនោះ វត្តមានរបស់ជនជាប់ចោទ អៀង ធីរិទ្ធគឺជាការចាំបាច់ ពីព្រោះយើងរំពឹងទុកថា សវនាការខាងមុខនឹងមានសំណួរ ឬបញ្ហាជាច្រើនដែលអាចចោទឡើង ហើយត្រូវការបកស្រាយជាចាំបាច់ដើម្បីឲ្យដឹងពីការពិតទាក់ទងនឹងបទចោទប្រកាន់របស់គាត់។ ដូចនេះ វត្តមានរបស់គាត់គឺជាការចាំបាច់ដោយខានមិនបាន, លោកប្រធាន"។ ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ឯកសារ E1/12.1 ទំព័រ ១២០ បន្ទាត់ ២០ ដល់ ទំព័រ ១២១ បន្ទាត់ ១, "[លោក ច័ន្ទ តារាស្មី ៖] អង្គសវនាការទាំងមូលជាទីគោរព។ សហព្រះរាជអាជ្ញាយល់ឃើញទៀតថា បន្ទាប់ពីពិនិត្យ ឬស្តាប់សាក្សីជំនាញ អៀង ធីរិទ្ធ អាចមើលស្គាល់បុគ្គលទាំងឡាយដែលធ្លាប់ស្គាល់ពីមុន បើទោះបីគាត់មិនអាចប្រាប់ឈ្មោះបុគ្គលទាំងនោះក៏ដោយ ប៉ុន្តែចំណុចនេះមានន័យថា គាត់អាចជួយពន្យល់ដល់អង្គសវនាការនៅពេលខាងមុខអំពីចម្លើយសាក្សី អំពីបុគ្គលដែលគាត់បានស្គាល់ ទាក់ទងនឹងបទចោទប្រកាន់ទាំងឡាយចំពោះគាត់បាន"។ *ដូចខាងលើ* ទំព័រ ១២៤ បន្ទាត់ ២៤ ដល់ទំព័រ ១២៥ បន្ទាត់ ៣, "[លោក ច័ន្ទ តារាស្មី ៖] នៅពេលសវនាការនៅពេលខាងមុខ អាចមានសំណួរ ឬបង្ហាញខ្លះដែលលើកឡើងដោយភាគីណាមួយអាចត្រូវការឆ្លើយបំភ្លឺពីជនជាប់ចោទ អៀង ធីរិទ្ធ"។ *ដូចខាងលើ* ទំព័រ ១២៤ បន្ទាត់ ២៤ ដល់ទំព័រ ១២៥ បន្ទាត់ ៣។

[៤៥] "លោក ស្រី SIMONNEAU-FORT ៖ សូមអរគុណលោកប្រធាន។ យើងចង់ដឹងពីគោលជំហររបស់មេធាវីការពារក្តីមុននឹងយើងបង្ហាញពីជំហររបស់យើង ហើយបើការនៅស្ងៀមមិនឆ្លើយតបជាសិទ្ធិរបស់ជនជាប់ចោទម្នាក់ៗនោះ ខ្ញុំគិតថាដើមបណ្តឹងរដ្ឋប្បវេណីជឿថា ដើម្បីជាការគោរពដល់ជនទាំងអស់ដែលបានចូលរួមនៅក្នុងសវនាការនេះ និងជាការគោរពដល់ប្រជាជនកម្ពុជាដែលពួកគេបង្ហាញថា គេស្រលាញ់ "យ៉ាងខ្លាំង"នោះ ខ្ញុំគិតថា យ៉ាងហោចណាស់ អ្វីដែលយើងអាចទទួលបានគឺការពន្យល់មួយចំនួននៅពេលចាប់ផ្តើមនៃសវនាការ។ យ៉ាងហោចណាស់ យើងសង្ឃឹមថាបានទទួលការពន្យល់ទាំងនោះ។ តាមពិត គេអាចប្រាប់ពីការពិត ដែលជាការប្រសើរ។ សូមអរគុណ"។ ប្រតិចារឹក ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ E1/15.1 ទំព័រ ៤៩ បន្ទាត់ ៤ ដល់ ១៥, "លោក ពេជ អង្គ ៖សូមអរគុណលោកប្រធាន។ ក្នុងឱកាសនៃការពិនិត្យភស្តុតាង និងដូចលោកស្រី Elisabeth Simomneau-Fort បានបញ្ជាក់រួចហើយ វាចាំបាច់ណាស់ថា ជនជាប់ចោទត្រូវផ្តល់សក្ខីកម្មពីព្រោះដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះទាំងអស់កំពុងរង់ចាំថាតើអ្នកដែលជាជនជាប់ចោទនោះមានអ្វីដែលនឹងត្រូវនិយាយ? ហើយប្រសិនបើមិននិយាយនោះ វាហាក់ដូចជាចង់បង្ហាញថា ខ្លួនឯងហ្នឹងបានទទួលខុស។ តាមពិត វាជាសិទ្ធិរបស់ជនជាប់ចោទ។ ដោយសារថា ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះបានរង់ចាំជាយូរមកហើយនេះ ជនជាប់ចោទគួរតែនិយាយ"។ ដូចខាងលើ ទំព័រ ៤៩ បន្ទាត់ ៤៩ ដល់ ទំព័រ ៥០ បន្ទាត់ ៣។

វដ្ឋធម្មនុញ្ញកម្ពុជា ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ កិច្ចព្រមព្រៀង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង គឺជាជំហរត្រឹមត្រូវឬទេ។

**អាស្រ័យហេតុនេះ** ដោយផ្អែកលើមូលហេតុទាំងអស់ដែលបានបញ្ជាក់ខាងលើ មេធាវីការពារក្តីស្នើដោយគោរពដល់អង្គជំនុំជម្រះសាលាដំបូងមេត្តា**បញ្ជាក់ឱ្យច្បាស់** ថា ៖

ក. ជនជាប់ចោទមានសិទ្ធិនៅស្ងៀមមិនឆ្លើយតប និងមានសិទ្ធិមិនដាក់ពិរុទ្ធភាពលើខ្លួនឯង

ខ. គេមិនអាចទាញសេចក្តីសន្និដ្ឋានដោយអវិជ្ជមានពីជនជាប់ចោទដែលប្រើសិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយតប និង

គ. គេមិនអាចទាញសេចក្តីសន្និដ្ឋានពីជនជាប់ចោទដែលប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតប នៅពេលសួរសំណួរទាក់ទងនឹងចំណុចអង្គហេតុមួយ ប៉ុន្តែផ្តល់សក្ខីកម្មលើចំណុចអង្គហេតុមួយផ្សេងទៀតទេ។

មេធាវីការពារក្តីសូមដាក់ជូនសំណើនេះដោយគោរព។

អាង ឧត្តម Michael G. KARNAVAS

សហមេធាវីការពារក្តី អៀង សារី

ចុះហត្ថលេខា នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី **៣១** ខែ **មករា ឆ្នាំ ២០១២**